# សំរិទ្ធិស័ក

SAMRITHISAK

ដើម្បីអាជីវកម្មឈានមុខគេជានិច្ច

# របាយការណ៍ប្រចាំឆ្នាំ

# ២០២៤

www.samrithisakmicrofinance.com.kh

# មាតិកា


| | |
|---|---|
| ទស្សនវិស័យ និង បេសកកម្ម | ០១ |
| សេចក្តីសង្ខេបអំពីគ្រឹះស្ថាន | ០១ |
| ទិដ្ឋភាពទូទៅរបស់សំរឹទ្ធិស័ក | ០២ |
| សូចនាករហិរញ្ញវត្ថុសង្ខេប | ០៤ |
| សង្ខេបព័ត៌មានឥណទាន | ០៥ |
| ព័ត៌មានគណៈគ្រប់គ្រងសំខាន់ៗ | ០៨ |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១១ |
| របាយការណ៍សវនករឯករាជ្យ | ១៦ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ២០ |
| របាយការណ៍ចំណូលលម្អិត | ២១ |
| របាយការណ៍បម្រែបម្រួលមូលធន | ២២ |
| របាយការណ៍លំហូរសាច់ប្រាក់ | ២៥ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ២៧ |
| អាស័យដ្ឋានការិយាល័យកណ្តាលនិងសាខា | ៦៣ |

# ទស្សនវិស័យ និង បេសកកម្ម

## ចក្ខុវិស័យ

ជម្រើសទីមួយរបស់អតិថិជនគឺមីក្រូហិរញ្ញវត្ថុ និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនាំមុខគេក្នុងការ ផ្តល់សេវាមីក្រូហិរញ្ញវត្ថុ។

## បេសកកម្ម

បេសកកម្មរបស់គ្រឹះស្ថាន គឺផ្តល់ឱកាសដល់ ប្រជា ពលរដ្ឋកម្ពុជា ក្នុងការកែលំអរជីវភាពរស់នៅតាមរយៈការទទួលយក សេវាមីក្រូហិរញ្ញវត្ថុ ដែលមានលក្ខណៈសមភាព និង ប្រកួតប្រជែងដោយ ធានាបាននូវនិរន្តភាព និងអត្ថប្រយោជន៍របស់អតិថិជន ភាគទុនិក បុគ្គលិក និងសង្គម។

# សេចក្តីសង្ខេបអំពីគ្រឹះស្ថាន

| | |
|---|---|
| ឈ្មោះគ្រឹះស្ថាន | ៖ គ្រឹះស្ថាន ស៊ីរីទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត |
| ប្រភេទអាជីវកម្ម | ៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ចុះបញ្ជីលេខ | ៖ ០០០៣២៤៨៩ |
| ការិយាល័យចុះបញ្ជី | ៖ ផ្ទះលេខ ៥០២ហេ្យ ៥០២ ហាស់ មហាវិថី ព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| សវនករឯករាជ្យ | ៖ KPMG Cambodia Ltd |
| បុគ្គលិក | ៖ ៩១ |

# ព័ត៌មានរបស់បុគ្គលិក

| បុគ្គលិក | | ការិយាល័យកណ្តាល | សាខា | មន្ត្រីឥណទាន |
|---|---|---|---|---|
| បុគ្គលិកសរុប | ៩១ | ៦៧ | ២៤ | ៩ |
| បុគ្គលិកនារី | ៣៣ | ៣១ | ២ | 0 |
| បុគ្គលិកប្រុស | ៥៣ | ៣៦ | ២២ | ៩ |

# ទិដ្ឋភាពទូទៅរបស់សំរិទ្ធិស័ក




**គ្រឹះស្ថាន សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត** ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់លោក **តាំង ខួន** និងវិនិយោគិនខ្មែរ ចំនួនបួននាក់ទៀតដើម្បីឱ្យគ្រឹះស្ថានមានដើមទុន និងធនធានគ្រប់គ្រាន់សំរាប់បម្រើដល់សេចក្តីត្រូវការ ខាងហិរញ្ញវត្ថុដល់អ្នកមានមុខរបរតូចតាច អ្នកជំនួញសហគ្រិន សិប្បករ អាជីវករ អ្នកផ្តល់សេវាកម្ម កសិករ និងអាជីវកម្មគ្រួសារជាដើម។ នៅក្នុងខែឧសភា ឆ្នាំ២០១០ ទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជាដែលមានឈ្មោះជាផ្លូវការថា៖

**សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត** និងមានដើមទុនចុះបញ្ជីចំនួន ៥០០.០០០ ដុល្លារអាមេរិក (ប្រាំរយពាន់ដុល្លារ អាមេរិក)។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ សំរិទ្ធិស័កបាន បន្ថែមដើមទុនរហូតដល់ ១.០០០.០០០ ដុល្លារអាមេរិក (មួយលានដុល្លារអាមេរិក)។ ដោយឃើញ នូវសេចក្តីត្រូវការខាងហិរញ្ញវត្ថុ យ៉ាងខ្លាំងរបស់អតិថិជន នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៩ សំរិទ្ធិស័ក ក៏សម្រេចចិត្តបន្ថែមដើមទុនរហូតដល់ ១៥.០០០.០០០ ដុល្លារអាមេរិក (ដប់ប្រាំលានដុល្លារអាមេរិក) ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ឥណទានជូនអតិថិជនរបស់ខ្លួន។

**សំរិទ្ធិស័ក** ត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយដល់ប្រជាពលរដ្ឋក្រីក្រដែលពុំអាចមានលទ្ធភាពទទួលសេវាហិរញ្ញវត្ថុពីធនាគារក្នុងការស្វែងរកទុនសម្រាប់បង្កើតនិងពង្រីកមុខរបររបស់ពួកគេ។

| ១៥,០០០,០០០ | ១៥,០០០,០០០ | ១៥,០០០,០០០ | ១៥,០០០,០០០ | ១៥,០០០,០០០ |
|---|---|---|---|---|
| ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |

# គ្រឹះស្ថាន សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត
## SAMRITHISAK MICROFINANCE LIMITED




CHAIRMAN BOARD OF DIRECTOR

តាំង-ឃុង

# សូចនាករហិរញ្ញវត្ថុសង្ខេប

| គិតជាដុល្លារអាមេរិក | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|
| **សមិទ្ធផលហិរញ្ញវត្ថុ** | | | |
| ចំណូលសរុប | ៣,៥០៤,៩០២ | ២,៩១៦,៧១៨ | ២,០៨២,២០១ |
| ចំណាយសរុប | ២,៨៩៨,០២០ | ២,៦៥៨,៦១៨ | ១,៥០៨,៣០៣ |
| **ប្រាក់ចំណេញ** | ៦០៦,៨៨២ | ២៥៨,១០០ | ៥៧៣,៨៩៨ |
| ទ្រព្យសកម្មសរុប | ២៤,៤៥០,៤៥៨ | ២០,៩០១,៦៨១ | ២១,៥០១,៧៩៤ |
| បំណុលសរុប | ៣,៨៦៦,១៣៤ | ១៤២,២២៨ | ១៦៨,៤៤៣ |
| មូលធនសរុប | ២០,៥៨៤,៣២៤ | ២០,៧៥៩,៤៥៣ | ២១,៣៣៣,៣៥១ |
| ដើមទុន | ១៥,០០០,០០០ | ១៥,០០០,០០០ | ១៥,០០០,០០០ |
| ចំណូលធៀបនិងទ្រព្យសកម្ម | ២.៤៨% | ១.២៣% | ២.៦៧% |
| ចំណូលធៀបនិងមូលធន | ២.៩៥% | ១.២៤% | ២.៦៩% |
| ឥណទាន និងបុរេប្រទានតាមថ្លៃដើមដករំលស់ | ២២,១៦៧,៦៩៩ | ១៥,៩៥០,៥៨៧ | ១០,៥០៧,០៩៩ |
| ចំនួនអតិថិជន | ១,៥៥០ | ១,១៦៦ | ៧៥៤ |
| ចំនួនមន្ត្រីឥណទាន | ២៩ | ២១ | ៩ |
| ចំនួនសាខា | ៦ | ៦ | ៣ |
| ឥណទានស្ថិតក្នុងហានិភ័យលើសពី ៣០ថ្ងៃ | ១២៦,៨៩៦ | ៦៩២,២៨៩ | ៤៣៦,០២៥ |



# សង្ខេបព័ត៌មាន ឥណទាន

## ឥណទានអាជីវកម្ម

ឥណទានអាជីវកម្ម គឺជាប្រភេទឥណទានដែលអតិថិជនយកទៅប្រើប្រាស់ដើម្បីពង្រីកមុខរបរ ឬដំណើរ ការអាជីវកម្មរបស់ខ្លួន និងដាក់ធានាអចលនទ្រព្យដូចជា ដី ដីនិងផ្ទះ ដីស្រែ ដីចំការ ឬតូបតាមបណ្តាផ្សារនានា។

### អត្ថប្រយោជន៍ដែលទទួលបាន

- ទំហំឥណទានរហូតដល់ ៣០០,០០០ ដុល្លារ ឬសមាមាត្រ ១,២០០,០០០,០០០រៀល
- អត្រាការប្រាក់១០.២០ភាគរយ រហូតដល់ ១៨ភាគរយ ក្នុងមួយឆ្នាំ
- រយៈពេលចាប់ពី ១៤ខែ ដល់ ១២០ខែ
- តម្រូវអោយមានទ្រព្យធានា
- ឯកសារតម្រូវងាយស្រួល។

### លក្ខណៈអតិថិជន

- អតិថិជនមានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ
- មានទីលំនៅពិតប្រាកដស្ថិតនៅរាជធានីភ្នំពេញ រឺបណ្តាខេត្តមួយចំនួន។

## ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន គឺជាឥណទានផ្តល់ជូនអតិថិជនជាសាច់ប្រាក់ដើម្បីយកទៅប្រើប្រាស់ តាមតម្រូវការផ្ទាល់ខ្លួនដែលមានដូចជា៖ ទិញអចលនទ្រព្យ គ្រឿងសង្ហារឹម និងសម្ភារៈផ្សេងៗ ជាច្រើនថែម ទៀតសម្រាប់ផ្គត់ផ្គង់ក្នុងជីវភាពរស់នៅ និងកែលម្អសេដ្ឋកិច្ចគ្រួសារឱ្យកាន់តែប្រសើរ។

### អត្ថប្រយោជន៍ដែលទទួលបាន

- ទំហំឥណទានរហូតដល់ ៣០០,០០០ដុល្លារ ឬ ១,២០០,០០០,០០០រៀល
- អត្រាការប្រាក់១០.២០ភាគរយ រហូតដល់ ១៨ភាគរយ ក្នុងមួយឆ្នាំ
- អាចបង់រំលស់ ១៤ខែ រហូតដល់ ១២០ ខែ
- អត្រាការប្រាក់សមរម្យ
- តម្រូវអោយមានទ្រព្យដាក់ធានា
- ការអនុម័តឥណទានឆាប់រហ័ស។

### លក្ខណៈអតិថិជន

- អតិថិជនមានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ
- មានទីលំនៅពិតប្រាកដស្ថិតនៅរាជធានីភ្នំពេញ រឺតាមបណ្តាខេត្តមួយចំនួន។

# ឥណទានបុគ្គលិក

ឥណទានបុគ្គលិកក្នុងគោលបំណង ទិញសំភារៈប្រើប្រាស់សម្រាប់បម្រើការងារជូនគ្រឹះស្ថាន ដោយមិនតំរូវដាក់ទ្រព្យធានាមានដូចជា (ទូរស័ព្ទ កុំព្យូទ័រ)។

## អត្ថប្រយោជន៍ដែលទទួលបាន

- ទំហំឥណទានរហូតដល់ ១,០០០ ដុល្លារ ឬសមាមាត្រ ៤,០០០,០០០រៀល
- អត្រាការប្រាក់ ១០ ភាគរយក្នុងមួយឆ្នាំ
- រយៈពេល ១៣ខែ រហូតដល់ ២៤ ខែ

## លក្ខណៈអតិថិជន

- បុគ្គលិកដែលបានបម្រើការងារចាប់ពី ១ឆ្នាំឡើង
- បុគ្គលិកមានស្នាដៃការងារល្អ
- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ។


សំរិទ្ធិស័ក
SAMRITHISAK
ឥណទាន
អាជីវកម្ម
BUSINESS LOAN
ទំហំកម្ចីរហូតដល់៖
$300,000
ទំនាក់ទំនង៖
097 761 3333 | 093 222 909

# ព័ត៌មានគណៈគ្រប់គ្រងសំខាន់ៗ



## លោក តាំង ហុង

### ប្រធានក្រុមប្រឹក្សាភិបាល

**លោក តាំង ហុង** ជាប្រធានក្រុម ប្រឹក្សាភិបាលរបស់ **ស៊ីរីទ្ធិស័ក** នៅឆ្នាំ ២០១៧។ គាត់កើតនៅឆ្នាំ ១៩៧០ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩៤ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិន ម្នាក់ដែលទទួលបានជោគជ័យ។ គាត់បាន បញ្ចប់បរិញ្ញាបត្រហិរញ្ញវត្ថុនិង ធនាគារ។

## លោក តាំង ខួន

### អគ្គនាយក

**លោក តាំង ខួន** ជាអនុប្រធានក្រុម ប្រឹក្សាភិបាលរបស់ **ស៊ីរីទ្ធិស័ក** នៅក្នុងឆ្នាំ ២០១៧។ គាត់បានកើតនៅឆ្នាំ ១៩៦៩ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ គាត់បាន បញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងទូទៅ។





## លោក លាង ចនពៅ

### សមាជិកក្រុមប្រឹក្សាភិបាល

**លោក លាង ចនពៅ** ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ **ស៊ីរីទ្ធិស័ក** ក្នុងឆ្នាំ ២០១០។ គាត់បានកើតនៅក្នុងឆ្នាំ ១៩៥៥ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជា វិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោកបានបញ្ចប់បរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម។

# គណៈកម្មាធិការប្រតិបត្តិ



## លោក តាំង ខួន
### អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

**លោក តាំង ខួន** ជាអនុប្រធានក្រុមប្រឹក្សាភិបាលរបស់ សុីរីទ្ធិស័ក ក្នុងឆ្នាំ ២០១៧។ គាត់បានកើតនៅឆ្នាំ ១៩៦៩ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោក តាំង ងួន បានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងទូទៅ។

## លោក ប៊ុន ជីដាទ
### អនុប្រធាននាយកប្រតិបត្តិ



**លោក ប៊ុន ជីដាទ** កើតនៅឆ្នាំ ១៩៨០ នៅខេត្តកំពង់ចាម។ លោកបានចូលបម្រើការងារជាមួយ**សុីរីទ្ធិស័ក** ក្នុងឆ្នាំ ២០១០ មានតួនាទីជាអនុប្រធាននាយកប្រតិបត្តិ។ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកធនាគារនិងហិរញ្ញវត្ថុ និង បានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងទូទៅ នៅសាកវិទ្យាល័យបៀលប្រាយ។ លោកបានចូលរួមវគ្គបណ្ដុះបណ្ដាលជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រង់។ មុនគាត់ចូលបំរើការងារក្នុង **សុីរីទ្ធិស័ក** គាត់ធ្លាប់បានបំរើការងារជាប្រធានទីផ្សារ នៅក្រុមហ៊ុនថៃសាវ៉ាកាលពីឆ្នាំ ២០០៤ នៅក្នុងប្រទេសកម្ពុជា។

# ភាគទុនិក



# របាយការណ៍របស់ ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើ សវនកម្មរួចរបស់ ស៊ីរីទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា (“ក្រុមហ៊ុន”) សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន រួមមានការធ្វើប្រតិបត្តិការក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗ ក្នុងវិសាលភាពនៃអាជ្ញាបណ្ណមីក្រូហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ត្រូវបានបង្ហាញនៅទំព័រទី១១។

## ដើមទុន

ពុំមានការប្រែប្រួលរចនាសម្ព័ន្ធភាគហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។ សូមមើលកំណត់សម្គាល់ 15 សម្រាប់ព័ត៌មានលម្អិត។

## ភាគលាភ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានការប្រកាស ឬបែងចែកភាគលាភឡើយ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមាន អនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 នោះឡើយ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និង សំវិធានធននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបាន ប៉ាន់ស្មានសមស្របសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ (ត)

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាច បណ្តាលឱ្យចំនួនទឹកប្រាក់នៃឥណទានអាក្រក់ដែលបានលុបចោល ឬចំនួនទឹកប្រាក់សំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងអស់ក្រៅពីឥណទាន ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាក្នុងតម្លៃរបស់វាដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានបន្ថយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឱ្យការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ហើយនឹងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និង បំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ គឺពុំមាន៖
(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ
(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុនឡើយ។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12ខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹង ប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍ជាសារវន្តផ្សេងទៀតកើតឡើងបន្ទាប់ពី កាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការលាតត្រដាង ឬកែតម្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

# ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបានបម្រើការនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| លោក តាំង ហុង | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក តាំង ងួន | អភិបាល |
| លោក លាង ចនពៅ | អភិបាល |
| លោក គុជ សេដ្ឋា | អភិបាល |
| លោក យឿន ប៊ុនយីម | អភិបាល |

# ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និង មិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុដល់ថ្ងៃចេញ របាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុង កាលបរិច្ឆេទហិរញ្ញវត្ថុ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

# ភាគកម្មរបស់អភិបាល

អភិបាលដែលកាន់មុខតំណែងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុ និង ភាគកម្មរបស់ពួកគាត់នៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | |
|---|---|---|---|---|---|---|
| | %នៃ កម្មសិទ្ធិ | ចំនួន ភាគហ៊ុន | ចំនួន ទឹកប្រាក់ ដុល្លារអាមេរិក | %នៃ កម្មសិទ្ធិ | ចំនួន ភាគហ៊ុន | ចំនួន ទឹកប្រាក់ ដុល្លារអាមេរិក |
| លោក តាំង ងួន | 58.00% | 87,000 | 8,700,000 | 58.00% | 87,000 | 8,700,000 |
| លោក តាំង ហុង | 37.67% | 56,500 | 5,650,000 | 37.67% | 56,500 | 5,650,000 |
| លោក លាង ចនពៅ | 3.67% | 5,500 | 550,000 | 3.67% | 5,500 | 550,000 |

# អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឱ្យទទួលបាននូវអត្ថប្រយោជន៍តាម មធ្យោបាយនៃការទិញភាគហ៊ុននោះឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវ អត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះ ឬដែលអភិបាលនោះមានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ លើរាល់ទិដ្ឋភាពជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

- អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ

- ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

- វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើស សមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

- ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែល ប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបាន ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

# ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ខ្ញុំបាទ តំណាងឱ្យក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី10 ដល់ទី53 ថាបានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

*ចុះហត្ថលេខាដោយយោងលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល*

លោក តាំង ហុង

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 28 ខែ មីនា ឆ្នាំ2025

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគទុនិករបស់
## សុរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត

# មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ សុរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត (ហៅកាត់ថា “ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពី បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី53 (ដែលហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”)។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម”)។

# មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈ គ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានបង្ហាញនៅទំព័រទី1 ដល់ទី5។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយ របាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោម ទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ ថាមានភាពចាំបាច់សម្រាប់ការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយ ដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការ នៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

# ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាម ស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវ ការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬ កំហុសឆ្គង ហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នាអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថា នឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នក ប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមន្ទិលធាតុនិយមក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុស ជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការ ក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាម នីតិវិធីនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានលើ ភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្ត បានកើតមានឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជា ជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។

- ធ្វើការវាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្តក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

**ត្នូ សុទ្ធី**

*Director*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី28 ខែមីនា ឆ្នាំ2025

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 5,889 | 23,703 | 3,618 | 14,780 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 759,785 | 3,058,135 | 772,431 | 3,155,381 |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | 8 | 9,955,702 | 40,071,701 | 3,514,574 | 14,357,035 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 10,367,958 | 41,731,031 | 15,950,587 | 65,158,148 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 12,137 | 48,851 | 87,032 | 355,526 |
| ទ្រព្យ និងបរិក្ខារ | 11 | 374,286 | 1,506,501 | 525,100 | 2,145,034 |
| ទ្រព្យសកម្មអរូបី | 12 | 4,682 | 18,845 | 5,804 | 23,709 |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 14ឃ | 21,355 | 85,954 | 42,535 | 173,755 |
| **ទ្រព្យសកម្មសរុប** | | 21,501,794 | 86,544,721 | 20,901,681 | 85,383,368 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | | - | - | 941 | 3,846 |
| បំណុលពន្ធលើ ប្រាក់ចំណេញប្រចាំឆ្នាំ | 14គ | 107,437 | 432,434 | 73,085 | 298,552 |
| បំណុលផ្សេងៗ | 13 | 61,006 | 245,549 | 68,202 | 278,604 |
| **បំណុលសរុប** | | 168,443 | 677,983 | 142,228 | 581,002 |
| **មូលធន** | | | | | |
| ដើមទុន | 15 | 15,000,000 | 60,675,000 | 15,000,000 | 60,675,000 |
| វិភាគទានដើមទុន | 16 | 1,328,630 | 5,370,504 | 1,328,630 | 5,370,504 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 17 | 136,939 | 555,751 | 115,588 | 468,831 |
| ប្រាក់ចំណេញរក្សាទុក | | 4,867,782 | 19,855,782 | 4,315,235 | 17,606,364 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | (590,299) | - | 681,667 |
| **មូលធនសរុប** | | 21,333,351 | 85,866,738 | 20,759,453 | 84,802,366 |
| **បំណុល និងមូលធនសរុប** | | 21,501,794 | 86,544,721 | 20,901,681 | 85,383,369 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## របាយការណ៍លទ្ធផលលម្អិត
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024

| | | 2024 | | 2023 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណូលការប្រាក់ | 18 | 2,037,330 | 8,293,970 | 2,811,090 | 11,553,580 |
| ចំណាយការប្រាក់ | 19 | - | - | (255,040) | (1,048,214) |
| **ចំណូលពីការប្រាក់សុទ្ធ** | | 2,037,330 | 8,293,970 | 2,556,050 | 10,505,366 |
| ចំណាយលើកម្រៃជើងសា និងប្រាក់កម្រៃសុទ្ធ | 20 | (4,789) | (19,496) | (6,105) | (25,091) |
| ចំណូលផ្សេងៗ | 21 | 44,871 | 182,670 | 86,876 | 357,060 |
| **ប្រាក់ចំណូលប្រតិបត្តិការសុទ្ធ** | | 2,077,412 | 8,457,144 | 2,636,821 | 10,837,335 |
| ការខាតបង់លើឱនភាពនៃតម្លៃ ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ | 9 | (34,448) | (140,238) | (131,776) | (541,599) |
| ចំណាយលើបុគ្គលិក | 22 | (773,988) | (3,150,905) | (1,431,198) | (5,882,224) |
| រំលស់ | 23 | (151,760) | (617,815) | (154,672) | (635,702) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | 24 | (382,757) | (1,558,204) | (529,187) | (2,174,958) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 734,459 | 2,989,982 | 389,988 | 1,602,852 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 14ខ | (160,561) | (653,644) | (131,888) | (542,060) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ** | | 573,898 | 2,336,338 | 258,100 | 1,060,792 |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | | |
| *ធាតុដែលមិនត្រូវបានធ្វើ ចំណាត់ថ្នាក់ឡើងវិញ ក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (1,271,966) | - | (663,077) |
| **លទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | 573,898 | 1,064,372 | 258,100 | 397,715 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024

| | ដើមទុន | | វិភាគទានដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងពីការវាយតម្លៃបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ថ្ងៃទី1 ខែមករា ឆ្នាំ2024 | 15,000,000 | 60,675,000 | 1,328,630 | 5,370,504 | 115,588 | 468,831 | 4,315,235 | 17,606,364 | - | 681,667 | 20,759,453 | 84,802,366 |
| ***ប្រតិបត្តិការបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន*** | | | | | | | | | | | | |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ 17) | - | - | - | - | 21,351 | 86,920 | (21,351) | (86,920) | - | - | - | - |
| | - | - | - | - | 21,351 | 86,920 | (21,351) | (86,920) | - | - | - | - |
| ***លទ្ធផលលម្អិតសរុប៖*** | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | 573,898 | 2,336,338 | - | - | 573,898 | 2,336,338 |
| លទ្ធផលលម្អិតផ្សេងៗ-លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (1,271,966) | - | (1,271,966) |
| **លទ្ធផលលម្អិតសរុប** | - | - | - | - | - | - | 573,898 | 2,336,338 | - | (1,271,966) | 573,898 | 1,064,372 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | 15,000,000 | 60,675,000 | 1,328,630 | 5,370,504 | 136,939 | 555,751 | 4,867,782 | 19,855,782 | - | (590,299) | 21,333,351 | 85,866,738 |
| ថ្ងៃទី1 ខែមករា ឆ្នាំ2023 | 15,000,000 | 60,675,000 | 1,411,601 | 5,711,515 | 168,133 | 684,791 | 4,004,590 | 16,329,612 | - | 1,344,744 | 20,584,324 | 84,745,662 |
| ***ប្រតិបត្តិការបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន*** | | | | | | | | | | | | |
| ការថយចុះនៃចំណែកវិភាគទានដើមទុន (កំណត់សម្គាល់ 16) | - | - | (82,971) | (341,011) | - | - | - | - | - | - | (82,971) | (341,011) |
| ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅ ប្រាក់ចំណេញរក្សាទុក (កំណត់សម្គាល់ 17) | - | - | - | - | (52,545) | (215,960) | 52,545 | 215,960 | - | - | - | - |
| | - | - | (82,971) | (341,011) | (52,545) | (215,960) | 52,545 | 215,960 | - | - | (82,971) | (341,011) |
| ***លទ្ធផលលម្អិតសរុប៖*** | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | 258,100 | 1,060,792 | - | - | 258,100 | 1,060,792 |
| លទ្ធផលលម្អិតផ្សេងៗ-លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (663,077) | - | (663,077) |
| **លទ្ធផលលម្អិតសរុប** | - | - | - | - | - | - | 258,100 | 1,060,792 | - | (663,077) | 258,100 | 397,715 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | 15,000,000 | 60,675,000 | 1,328,630 | 5,370,504 | 115,588 | 468,831 | 4,315,235 | 17,606,364 | - | 681,667 | 20,759,453 | 84,802,366 |


សំរិទ្ធិស័ក
SAMRITHISAK
ឥណទាន
ប្រើប្រាស់ផ្ទាល់ខ្លួន
ទំហំកម្ចី
រហូតដល់
$50,000
អត្រាការប្រាក់សមរម្យ
ការអនុម័តកម្ចីលឿន
បត់បែនក្នុងការសងត្រឡប់
097 761 3333 | 093 222 909



# ឥណទានអាជីវកម្ម កម្ចីរហូតដល់

# $300,000

## របាយការណ៍លំហូរទឹកប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024

| | កំណត់សម្គាល់ | 2024 ដុល្លារអាមេរិក | 2024 ពាន់រៀល (កំណត់សម្គាល់ 5) | 2023 ដុល្លារអាមេរិក | 2023 ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | | 573,898 | 2,336,338 | 258,100 | 1,060,792 |
| *និយ័តភាពលើ៖* | | | | | |
| ចំណូលការប្រាក់ | 18 | (2,037,330) | (8,293,970) | (2,811,090) | (11,553,580) |
| ចំណាយការប្រាក់ | 19 | - | - | 255,040 | 1,048,214 |
| ការខាតបង់លើឱនភាពនៃតម្លៃ ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ | 9 | 34,448 | 140,238 | 131,776 | 541,599 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 14ខ | 160,561 | 653,644 | 131,888 | 542,060 |
| រំលស់ | 23 | 151,760 | 617,815 | 154,672 | 635,702 |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | | 39,691 | 161,582 | 67,421 | 277,100 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | | (18,303) | (74,512) | (53,636) | (220,444) |
| ឱនភាពនៃតម្លៃលើទ្រព្យ និងបរិក្ខារ | | - | - | 37,210 | 152,933 |
| ខាតពីការលុបចោលទ្រព្យ និបរិក្ខារ | | - | - | 30,942 | 127,171 |
| ខាតពីការប្តូររូបិយប័ណ្ណបរទេស មិនបានទទួលស្គាល់ | | - | - | 513 | 2,108 |
| | | (1,095,275) | (4,458,865) | (1,797,164) | (7,386,345) |
| *បម្រែបម្រួលនូវ៖* | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | 5,478,575 | 22,303,279 | 5,868,705 | 24,120,378 |
| ទ្រព្យសកម្មផ្សេងៗ | | 74,895 | 304,898 | 28,618 | 117,620 |
| ប្រាក់បញ្ញើមានកាលកំណត់ រយៈពេលខ្លី | | 853,431 | 3,474,318 | - | - |
| បំណុលផ្សេងៗ | | (7,196) | (29,295) | (17,371) | (71,395) |
| សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ | | 5,304,430 | 21,594,335 | 4,082,788 | 16,780,258 |
| ការប្រាក់បានទទួល | | 2,073,105 | 8,439,610 | 2,832,307 | 11,640,782 |
| ការប្រាក់បានបង់ | | - | - | (385,565) | (1,584,672) |
| ពន្ធលើប្រាក់ចំណេញបានបង់ | 14គ | (105,029) | (427,573) | (171,819) | (706,176) |
| កាតព្វកិច្ចអត្ថប្រយោជន៍ និយោជិតបានបង់ | | (40,632) | (165,413) | (72,484) | (297,909) |
| សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពប្រតិបត្តិការ | | 7,231,874 | 29,440,959 | 6,285,227 | 25,832,283 |

## របាយការណ៍លំហូរទឹកប្រាក់ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024

| | | 2024 | | 2023 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | - | - | (44,384) | (182,418) |
| សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ | | 18,493 | 75,285 | 53,636 | 220,444 |
| ការដាក់ប្រាក់បញ្ញើមានកាលកំណត់ | | (11,503,000) | (46,828,713) | - | - |
| ការដកប្រាក់បញ្ញើមានកាលកំណត់ | | 5,350,000 | 21,779,850 | - | - |
| សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ ទទួលបានពីសកម្មភាពវិនិយោគ | | (6,134,507) | (24,973,578) | 9,252 | 38,026 |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់សងប្រាក់កម្ចី | | - | - | (3,591,955) | (14,762,935) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពហិរញ្ញប្បទាន | | - | - | (3,591,955) | (14,762,935) |
| **ការកើនឡើងសុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 1,097,367 | 4,467,381 | 2,702,524 | 11,107,374 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី1 ខែមករា** | | 3,540,623 | 14,463,446 | 838,099 | 3,450,454 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (262,916) | - | (94,382) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី31 ខែធ្នូ** | 26 | 4,637,990 | 18,667,911 | 3,540,623 | 14,463,446 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024

កំណត់សម្គាល់ទាំងនេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយគួរតែត្រូវបានអានជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

## ១. អំពីក្រុមហ៊ុន

ស៊ីទីទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត (ហៅកាត់ថា “ក្រុមហ៊ុន”) គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមការចុះបញ្ជីលេខ 00032489 ចុះថ្ងៃទី4 ខែមីនា ឆ្នាំ2010 ចេញដោយក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី25 ខែឧសភា ឆ្នាំ2010 ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន រួមមានការធ្វើប្រតិបត្តិការក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និង ការផ្តល់នូវសេវាកម្ម ហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗ ក្នុងវិសាលភាពនៃអាជ្ញាបណ្ណមីក្រូហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ក្រុមហ៊ុនមានសាខាចំនួន 3 សាខា (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023៖ 4 សាខា)។
គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ក្រុមហ៊ុនមាននិយោជិតចំនួន 86 នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023៖ 124 នាក់)។

## ២. មូលដ្ឋាននៃការរៀបចំ

### ក. របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម”)។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានអនុម័តឱ្យ បោះផ្សាយដោយក្រុមប្រឹក្សាភិបាលនៅ ថ្ងៃទី28 ខែមីនា ឆ្នាំ2025។

ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ 29។

## ២. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានថ្លៃដើមដំបូង។

# ៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាពីររូបិយប័ណ្ណ គឺប្រាក់រៀលខ្មែរ និងប្រាក់ដុល្លារអាមេរិក។ អ្នកគ្រប់គ្រងបានកំណត់ថា ប្រាក់ដុល្លារអាមេរិក គឺជារូបិយប័ណ្ណមុខងារ និងជា រូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិកដែលជិតបំផុត ឬមួយពាន់រៀល លុះត្រាតែមានការបង្ហាញផ្សេងពីនោះ។

# ៤. ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមាន ផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទស្សនៈវិស័យ។

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឱ្យមាននិយ័តភាពនៅក្នុងការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ដែលទាក់ទងនឹងឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញដូចខាងក្រោម៖

► កំណត់សម្គាល់ 29ខ(vii). ការកំណត់អត្តសញ្ញាណ និងការវាស់វែងឱនភាពនៃតម្លៃ។

## ៥. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោម ទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ផ្នែកទី30 ការប្តូររូបិយប័ណ្ណបរទេស ។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗ ត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូររូបិយប័ណ្ណទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ដែលអត្រានេះត្រូវបានចាត់ទុកថាមានលក្ខណៈសមស្រប ពីព្រោះអត្រានេះមិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា “លម្អៀងពីការប្តូររូបិយប័ណ្ណ” នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោម៖

| **ការិយបរិច្ឆេទហិរញ្ញវត្ថុដែលបានបញ្ចប់** | | | **អត្រានាកាលបរិច្ឆេទរាយការណ៍** | **អត្រាមធ្យម** |
|---|---|---|---|---|
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | 1 ដុល្លារអាមេរិក | = | 4,025 រៀល | 4,071 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | 1 ដុល្លារអាមេរិក | = | 4,085 រៀល | 4,110 រៀល |

ការប្តូររូបិយប័ណ្ណនេះ មិនគួរត្រូវបានយកមកបកស្រាយថាតួលេខប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានប្តូរទៅជា ប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

# ៦. សាច់ប្រាក់ក្នុងដៃ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោម ទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ផ្នែកទី30 ការប្តូររូបិយប័ណ្ណបរទេស ។

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| សាច់ប្រាក់បន្តិចបន្តួច | 5,889 | 23,703 | 3,618 | 14,780 |

# ៧. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| គណនីចរន្ត | (i) | 9,785 | 39,385 | 22,431 | 91,631 |
| ប្រាក់តម្កល់ធានាលើដើមទុន | (ii) | 750,000 | 3,018,750 | 750,000 | 3,063,750 |
| | | 759,785 | 3,058,135 | 772,431 | 3,155,381 |

(i) គណនីចរន្តដែលបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា មិនទទួលបានការប្រាក់នោះឡើយ (ឆ្នាំ2023៖ គ្មាន)។

(ii) យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-01-136 ចុះថ្ងៃទី15 ខែតុលា ឆ្នាំ2001 គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុតម្រូវឱ្យរក្សាទុកប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 5% នៃដើមទុនចុះបញ្ជីជាមួយនឹងធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចយកមកប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ ក្រុមហ៊ុន បានឡើយ ប៉ុន្តែក្រុមហ៊ុនអាចដកមកវិញបាន នៅពេលដែលក្រុមហ៊ុនសម្រេចចិត្តឈប់ធ្វើ អាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រាក់តម្កល់ធានាដើមទុន ទទួលបានអត្រាការប្រាក់ 1.31% (ឆ្នាំ2023៖ 0.37%) ក្នុងមួយឆ្នាំ។

## ៨. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| គណនីចរន្ត | 3,760,664 | 15,136,673 | 3,412,060 | 13,938,265 |
| គណនីសន្សំ | 8,221 | 33,090 | 102,514 | 418,770 |
| ប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដើមតិចជាង ឬស្មើ 3ខែ | 853,431 | 3,435,060 | - | - |
| ប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដើមលើសពី 3ខែ | 5,333,386 | 21,466,878 | - | - |
| | 9,955,702 | 40,071,701 | 3,514,574 | 14,357,035 |

អត្រាការប្រាក់ប្រចាំឆ្នាំ ដែលទទួលបានចំពោះសមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានានៅចុងការិយបរិច្ឆេទមានដូចខាងក្រោមៈ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 |
|---|---|---|
| គណនីចរន្ត | សូន្យ | សូន្យ |
| គណនីសន្សំ | សូន្យ – 1% | សូន្យ – 0.5% |
| ប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដើមតិចជាង ឬស្មើ 3ខែ | 1.50% – 3.00% | មិនមាន |
| ប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដើមលើសពី 3ខែ | 2.25% – 5.00% | មិនមាន |

## ៩. ឥណទានផ្តល់ដល់អតិថិជន

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ឥណទានបុគ្គល | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |
| ដកៈ សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ | (127,297) | (512,370) | (166,758) | (681,206) |
| | 10,367,958 | 41,731,031 | 15,950,587 | 65,158,148 |

បម្រែបម្រួលសំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃក្នុងអំឡុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| នាថ្ងៃទី1 ខែមករា | 166,758 | 681,206 | 92,214 | 379,645 |
| ទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទ | 66,479 | 270,636 | 150,484 | 618,489 |
| ការលុបចោលក្នុងអំឡុងការិយបរិច្ឆេទ | (105,940) | (431,282) | (75,940) | (312,113) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (8,190) | - | (4,815) |
| នាថ្ងៃទី31 ខែធ្នូ | 127,297 | 512,370 | 166,758 | 681,206 |

ព័ត៌មានលម្អិតនៃការខាតបង់លើឱនភាពនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធមានដូចខាងក្រោម៖

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ការខាតបង់ឱនភាពនៃតម្លៃលើ ទ្រព្យសកម្មហិរញ្ញវត្ថុ | 66,479 | 270,636 | 150,484 | 618,489 |
| ការប្រមូលបានមកវិញនូវឥណទាន ដែលបានលុបចេញពីបញ្ជី | (32,031) | (130,398) | (18,708) | (76,890) |
| | 34,448 | 140,238 | 131,776 | 541,599 |

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ក. តាមកាលវសាន៖** | | | | |
| រយៈពេល 1ខែ | - | - | 6,054 | 24,731 |
| ពី 2 ទៅ 3ខែ | - | - | 8,520 | 34,804 |
| ពី 4 ទៅ 12ខែ | 3,182 | 12,808 | 151,142 | 617,415 |
| លើសពី 12ខែ | 10,492,073 | 42,230,593 | 15,951,629 | 65,162,404 |
| | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |
| **ខ. តាមរូបិយប័ណ្ណ៖** | | | | |
| ដុល្លារអាមេរិក | 9,370,794 | 37,717,446 | 14,244,401 | 58,188,378 |
| ប្រាក់រៀល | 1,124,461 | 4,525,955 | 1,872,944 | 7,650,976 |
| | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |

# ៩. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖ (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **គ. តាមវិស័យសេដ្ឋកិច្ច៖** | | | | |
| ឥណទានប្រើប្រាស់ | 6,149,185 | 24,750,470 | 7,987,503 | 32,628,950 |
| ការជួញដូរ និងពាណិជ្ជកម្ម | 2,610,687 | 10,508,015 | 4,961,308 | 20,266,943 |
| សេវាកម្ម | 1,123,483 | 4,522,019 | 1,620,421 | 6,619,419 |
| ការដឹកជញ្ជូន | 209,088 | 841,579 | 499,268 | 2,039,510 |
| កសិកម្ម | 122,426 | 492,765 | 307,814 | 1,257,420 |
| សំណង់ | 46,190 | 185,915 | 138,274 | 564,849 |
| ផលិតកម្ម | 23,325 | 93,883 | 32,127 | 131,239 |
| ផ្សេងៗ | 210,871 | 848,755 | 570,630 | 2,331,024 |
| | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |
| **ឃ. តាមនិវាសនដ្ឋាន៖** | | | | |
| និវាសនជន | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |
| **ង. តាមទំនាក់ទំនង៖** | | | | |
| អតិថិជនខាងក្រៅ | 10,340,080 | 41,618,822 | 15,944,501 | 65,133,286 |
| បុគ្គលិក | 155,175 | 624,579 | 172,844 | 706,068 |
| | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |
| **ច. តាមការធានា/មិនមានការធានា៖** | | | | |
| មានការធានា | 10,424,366 | 41,958,073 | 16,020,518 | 65,443,816 |
| មិនមានការធានា | 70,889 | 285,328 | 96,827 | 395,538 |
| | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |

# ៩. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖ (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ឆ. តាមកាលកំណត់សង** | | | | |
| ឥណទានរយៈពេលច្រើនជាង 1ឆ្នាំ៖ | | | | |
| តិចជាង 30ថ្ងៃ | 10,045,028 | 40,431,237 | 15,398,092 | 62,901,206 |
| ចាប់ពី 30ថ្ងៃ ទៅ 89ថ្ងៃ | 301,405 | 1,213,155 | 521,584 | 2,130,671 |
| ចាប់ពី 90ថ្ងៃ ទៅ 179ថ្ងៃ | 69,904 | 281,364 | 81,377 | 332,425 |
| ចាប់ពី 180ថ្ងៃ ទៅ 359ថ្ងៃ | 78,918 | 317,645 | 116,292 | 475,052 |
| លើសពី 359ថ្ងៃ | - | - | - | - |
| | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |
| **ជ. តាមការធ្វើសម្បទាន៖** | | | | |
| បានរៀបចំឡើងវិញ (*) | 2,075,934 | 8,355,634 | 2,181,954 | 8,913,282 |
| មិនបានរៀបចំឡើងវិញ | 8,419,321 | 33,887,767 | 13,935,391 | 56,926,072 |
| | 10,495,255 | 42,243,401 | 16,117,345 | 65,839,354 |

(*) "ឥណទានរៀបចំឡើងវិញ" គឺជាឥណទានដែលលក្ខខណ្ឌ នៃកិច្ចសន្យាត្រូវបានកែប្រែដើម្បីផ្តល់នូវលក្ខខណ្ឌអនុគ្រោះ សម្រាប់អ្នកខ្ចីក្នុងហេតុផលសមស្របទាក់ទងនឹងភាពប្រាកដប្រជានៃវិបត្តិហិរញ្ញវត្ថុបណ្តោះអាសន្ន។

**ឈ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)**

អត្រាការប្រាក់ប្រចាំឆ្នាំលើឥណទានផ្តល់ដល់អតិថិជននាចុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 |
|---|---|---|
| អតិថិជនខាងក្រៅ | 9.00% -18.00% | 9.00% -18.00% |
| បុគ្គលិក | 9.00% -12.00% | 6.00% -12.00% |

# ១០. ទ្រព្យសកម្មផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ប្រាក់បង់មុន | 5,686 | 22,886 | 6,012 | 24,559 |
| បុរេប្រទាន និងប្រាក់តម្កល់ | 4,900 | 19,723 | 12,807 | 52,317 |
| ផ្សេងៗ | 1,551 | 6,242 | 68,213 | 278,650 |
| | 12,137 | 48,851 | 87,032 | 355,526 |

# ១១. ទ្រព្យ និងបរិក្ខារ

| 2024 | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | 259,590 | 555,272 | 127,831 | 162,995 | 54,745 | 1,160,433 | 4,740,369 |
| ការលក់ | - | - | (46,757) | - | (21,106) | (67,863) | (276,270) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | (66,505) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | 259,590 | 555,272 | 81,074 | 162,995 | 33,639 | 1,092,570 | 4,397,594 |
| ដក៖ **រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | 145,974 | 168,085 | 121,671 | 145,713 | 53,890 | 635,333 | 2,595,335 |
| រំលស់ក្នុងការិយបរិច្ឆេទ (កំណត់សម្គាល់ 23) | 43,657 | 92,715 | 4,954 | 8,805 | 507 | 150,638 | 613,247 |
| ការលក់ | - | - | (46,757) | - | (20,930) | (67,687) | (275,554) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | (41,935) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | 189,631 | 260,800 | 79,868 | 154,518 | 33,467 | 718,284 | 2,891,093 |
| **តម្លៃយោង** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | 113,616 | 387,187 | 6,160 | 17,282 | 855 | 525,100 | 2,145,034 |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | 69,959 | 294,472 | 1,206 | 8,477 | 172 | 374,286 | 1,506,501 |

(*) នៅក្នុងទ្រព្យ និងបរិក្ខារ មានធាតុដែលមានថ្លៃដើមចំនួន 356,989 ដុល្លារអាមេរិក ដែលត្រូវបានរំលស់ពេញអាយុកាលនៅថ្ងៃទី31 ខែធ្នូ ឆ្នាំ 2024 (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023៖ 370,393 ដុល្លារអាមេរិក) ប៉ុន្តែទ្រព្យ និងបរិក្ខារទាំងនេះបានកំពុងប្រើប្រាស់យ៉ាងសកម្មនៅឡើយ។

# ១១. ទ្រព្យ និងបរិក្ខារ (ត)

| 2023 | ការកែលម្អទ្រព្យជួល ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារការិយាល័យ ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 373,743 | 710,378 | 127,831 | 162,558 | 54,745 | 1,429,255 | 5,884,246 |
| ការទិញបន្ថែម | 35,712 | 1,324 | - | 7,348 | - | 44,384 | 182,418 |
| ការលុបចោល | (149,865) | - | - | (6,911) | - | (156,776) | (644,349) |
| ការលក់ | - | (156,430) | - | - | - | (156,430) | (642,927) |
| លម្អៀងពីការប្តូរូបិយប័ណ្ណ | - | - | - | - | - | - | (39,019) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | 259,590 | 555,272 | 127,831 | 162,995 | 54,745 | 1,160,433 | 4,740,369 |
| ដក៖ **រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 195,281 | 229,123 | 111,700 | 139,479 | 51,250 | 726,833 | 2,992,375 |
| រំលស់ក្នុងការិយបរិច្ឆេទ (កំណត់សម្គាល់ 23) | 32,406 | 95,392 | 9,971 | 13,145 | 2,640 | 153,554 | 631,107 |
| ការលុបចោល | (118,923) | - | - | (6,911) | - | (125,834) | (517,178) |
| ការលក់ | - | (156,430) | - | - | - | (156,430) | (642,927) |
| ឱនភាពនៃតម្លៃ | 37,210 | - | - | - | - | 37,210 | 152,933 |
| លម្អៀងពីការប្តូរូបិយប័ណ្ណ | - | - | - | - | - | - | (20,975) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | 145,974 | 168,085 | 121,671 | 145,713 | 53,890 | 635,333 | 2,595,335 |
| **តម្លៃយោង** | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 178,462 | 481,255 | 16,131 | 23,079 | 3,495 | 702,422 | 2,891,871 |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | 113,616 | 387,187 | 6,160 | 17,282 | 855 | 525,100 | 2,145,034 |

## ១២. ទ្រព្យសកម្មអរូបី

| កុំព្យូទ័រសូហ្វវែរ និងអាជ្ញាបណ្ណ | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី1 ខែមករា | 13,230 | 54,045 | 13,230 | 53,899 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (794) | - | 146 |
| នាថ្ងៃទី31 ខែធ្នូ | 13,230 | 53,251 | 13,230 | 54,045 |
| ដកៈ **រំលស់បង្គរ** | | | | |
| នាថ្ងៃទី1 ខែមករា | 7,426 | 30,336 | 6,308 | 25,970 |
| រំលស់ក្នុងការិយបរិច្ឆេទ (កំណត់សម្គាល់ 23) | 1,122 | 4,568 | 1,118 | 4,595 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (498) | - | (229) |
| នាថ្ងៃទី31 ខែធ្នូ | 8,548 | 34,406 | 7,426 | 30,336 |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី1 ខែមករា | 5,804 | 23,709 | 6,922 | 27,929 |
| នាថ្ងៃទី31 ខែធ្នូ | 4,682 | 18,845 | 5,804 | 23,709 |

## ១៣. បំណុលផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណាយបង្គរ | 22,161 | 89,198 | 20,148 | 82,304 |
| ពន្ធត្រូវបង់ទាត់ | 6,394 | 25,736 | 18,211 | 74,392 |
| គណនីត្រូវទូទាត់ផ្សេងៗ | 32,451 | 130,615 | 29,843 | 121,908 |
| | 61,006 | 245,549 | 68,202 | 278,604 |

# ១៤. ពន្ធលើប្រាក់ចំណេញ

## ក. អត្រាពន្ធផ្លូវការ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញសាជីវកម្ម ដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមា ដោយគណនាតាមអត្រា 1% នៃប្រាក់ចំណូលសរុប ទៅតាមចំនួនមួយណាដែលធំជាង។

## ខ. ចំណាយពន្ធលើប្រាក់ចំណេញ

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ពន្ធប្រចាំឆ្នាំ | 128,096 | 521,479 | 110,707 | 455,006 |
| សំវិធានធនខ្វះក្នុងការិយបរិច្ឆេទមុន | 11,285 | 45,941 | 11,645 | 47,861 |
| ចំណាយលើពន្ធពន្យារ | 21,180 | 86,224 | 9,536 | 39,193 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 160,561 | 653,644 | 131,888 | 542,060 |

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញដែលត្រូវបានគណនាតាមអត្រាពន្ធផ្លូវការ 20% ធៀបទៅនឹងចំណាយពន្ធលើប្រាក់ចំណេញ ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត មានដូចខាងក្រោម៖

| | 2024 | | | 2023 | | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | % | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | % |
| ប្រាក់ចំណេញមុនដកពន្ធ | 734,459 | 2,989,982 | | 389,988 | 1,602,852 | |
| ពន្ធលើប្រាក់ចំណេញតាមអត្រាពន្ធផ្លូវការ 20% | 146,892 | 597,997 | 20.00 | 77,998 | 320,572 | 20 |
| ចំណាយមិនអាចកាត់កងបាន | 2,384 | 9,706 | 0.32 | 42,245 | 173,627 | 11 |
| សំវិធានធនខ្វះក្នុងការិយបរិច្ឆេទមុន | 11,285 | 45,941 | 1.54 | 11,645 | 47,861 | 3 |
| | 160,561 | 653,644 | 21.86 | 131,888 | 542,060 | 34 |

ការគណនាប្រាក់ចំណេញជាប់ពន្ធ គឺស្ថិតក្រោមការត្រួតពិនិត្យ និងវាយតម្លៃចុងក្រោយពីអាជ្ញាធរពន្ធដារ។

## គ. បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| នាថ្ងៃទី1 ខែមករា | 73,085 | 298,552 | 122,552 | 504,547 |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | 128,096 | 521,479 | 110,707 | 455,006 |
| សំវិធានធនខ្វះក្នុងការិយបរិច្ឆេទមុន | 11,285 | 45,941 | 11,645 | 47,861 |
| ពន្ធលើប្រាក់ចំណេញបានបង់ | (105,029) | (427,573) | (171,819) | (706,176) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (5,965) | - | (2,686) |
| នាថ្ងៃទី31 ខែធ្នូ | 107,437 | 432,434 | 73,085 | 298,552 |

## ឃ. ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ពន្ធពន្យារជាទ្រព្យសកម្ម | 35,951 | 144,703 | 62,401 | 254,908 |
| បំណុលពន្ធពន្យារ | (14,596) | (58,749) | (19,866) | (81,153) |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 21,355 | 85,954 | 42,535 | 173,755 |

ពន្ធពន្យារជាទ្រព្យសកម្ម/(បំណុល) រួមមាន៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| រំលស់ | (12,217) | (49,173) | (19,866) | (81,153) |
| ខាតពីការប្តូររូបិយប័ណ្ណបរទេសដែលមិនទាន់ទទួលស្គាល់ | (2,379) | (9,576) | 103 | 421 |
| កម្រៃឥណទានមិនទាន់បានរំលស់ | 21,307 | 85,761 | 42,612 | 174,070 |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | - | 188 | 768 |
| សំវិធានធនលើការខាតបង់ឱនភាពតម្លៃ | 14,644 | 58,942 | 19,498 | 79,649 |
| | 21,355 | 85,954 | 42,535 | 173,755 |

បម្រែបម្រួលពន្ធពន្យារជាទ្រព្យសកម្មសុទ្ធរួមមាន៖

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| នាថ្ងៃទី1 ខែមករា | 42,535 | 173,755 | 52,071 | 214,376 |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | (21,180) | (86,224) | (9,536) | (39,193) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (1,577) | - | (1,428) |
| នាថ្ងៃទី31 ខែធ្នូ | 21,355 | 85,954 | 42,535 | 173,755 |

# ១៥. ដើមទុន

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ 5) |
| បានចុះបញ្ជី បោះផ្សាយ និងបង់គ្រប់ចំនួន 150,000 ភាគហ៊ុនដែលមានតម្លៃចារិក 100 ដុល្លារអាមេរិកក្នុងមួយហ៊ុន | 15,000,000 | 60,675,000 | 15,000,000 | 60,675,000 |

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ភាគទុនិករបស់ក្រុមហ៊ុន និងភាគកម្មមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | |
|---|---|---|---|---|---|---|
| | % នៃ កម្មសិទ្ធិ | ចំនួន ភាគហ៊ុន | ចំនួន ដុល្លារអាមេរិក | % នៃ កម្មសិទ្ធិ | ចំនួន ភាគហ៊ុន | ចំនួន ដុល្លារអាមេរិក |
| លោក តាំង ងួន | 58.00% | 87,000 | 8,700,000 | 58.00% | 87,000 | 8,700,000 |
| លោក តាំង ហុង | 37.67% | 56,500 | 5,650,000 | 37.67% | 56,500 | 5,650,000 |
| លោក លាង ចនពៅ | 3.67% | 5,500 | 550,000 | 3.67% | 5,500 | 550,000 |
| លោក ភួន ធីទៀង | 0.33% | 500 | 50,000 | 0.33% | 500 | 50,000 |
| លោក ប៊ុន ជីជាវ | 0.33% | 500 | 50,000 | 0.33% | 500 | 50,000 |
| | 100% | 150,000 | 15,000,000 | 100% | 150,000 | 15,000,000 |
| សមមូលពាន់រៀល (កំណត់សម្គាល់ 5) | | | 60,675,000 | | | 60,675,000 |

ពុំមានការប្រែប្រួលភាគទុនិក និងរចនាសម្ព័ន្ធភាគហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

# ១៦. វិភាគទានដើមទុន

វិភាគទានដើមទុន គឺជាភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ននៃការទូទាត់នាពេលអនាគត ដែលត្រូវបានធ្វើអប្បហារក្នុងអត្រាការប្រាក់តាមទីផ្សារសម្រាប់ប្រាក់កម្ចីស្រដៀងគ្នា និងតម្លៃដែលទទួលបានពីប្រាក់កម្ចីពីភាគទុនិក។ ប្រាក់កម្ចីនេះត្រូវបានទូទាត់សងមុនកាលវសាននៅថ្ងៃទី24 ខែមេសា ឆ្នាំ2023 ហេតុដូច្នេះទឹកប្រាក់ចំនួន 82,971 ដុល្លារអាមេរិក ត្រូវបានដកពីវិភាគទានដើមទុនបន្ទាប់ពីការធ្វើការវាស់វែងឡើងវិញនៅការិយបរិច្ឆេទ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ។

# ១៧. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ សំដៅទៅលើភាពខុសគ្នានៃសំវិធានធនរវាងឱនភាពនៃតម្លៃលើឥណទាន ស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ.ក

សម្រាប់ ស.ត.ម។) និងការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ ដោយអនុលោមតាមធនាគារជាតិនៃកម្ពុជា។

នៅក្នុងឆ្នាំ2024 ក្រុមហ៊ុនបានផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅគណនីទុនបម្រុងតាមបទប្បញ្ញត្តិចំនួន 21,351 ដុល្លារអាមេរិក (ឆ្នាំ2023៖ បានផ្ទេរពីគណនីទុនបម្រុងតាមបទប្បញ្ញត្តិទៅប្រាក់ចំណេញរក្សាទុកចំនួន 52,545 ដុល្លារអាមេរិក)។

| | សមតុល្យនៅ ធនាគារ និង គ្រឹះស្ថាន ហិរញ្ញវត្ថុនានា ដុល្លារអាមេរិក | ឥណទាន ផ្តល់ដល់អតិថិជន ដុល្លារអាមេរិក | ទ្រព្យសកម្ម ផ្សេងៗ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | | | |
| សំវិធានធនតាមធនាគារជាតិនៃកម្ពុជា | 99,552 | 164,684 | - | 264,236 |
| សំវិធានធនតាម ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម (កំណត់សម្គាល់9) | - | 127,297 | - | 127,297 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ (ក) | | | | 136,939 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | | | | |
| សំវិធានធនតាមធនាគារជាតិនៃកម្ពុជា | 35,146 | 247,071 | 129 | 282,346 |
| សំវិធានធនតាម ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម | - | 166,758 | - | 166,758 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ (ខ) | | | | 115,588 |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ (ក) – (ខ) | | | | 21,351 |
| សមមូលពាន់រៀល (កំណត់សម្គាល់ 5) | | | | 86,920 |

## ១៨. ចំណូលការប្រាក់

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ឥណទានផ្តល់ដល់អតិថិជន | 1,901,063 | 7,739,227 | 2,801,721 | 11,515,073 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 9,853 | 40,112 | 9,365 | 38,490 |
| សមតុល្យនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា | 126,414 | 514,631 | 4 | 17 |
| | 2,037,330 | 8,293,970 | 2,811,090 | 11,553,580 |

## ១៩. ចំណាយការប្រាក់

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ប្រាក់កម្ចី | - | - | 255,040 | 1,048,214 |

## ២០. ចំណាយលើកម្រៃជើងសា និងប្រាក់កម្រៃសុទ្ធ

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណូលលើកម្រៃជើងសា និង ប្រាក់កម្រៃ | - | - | 44 | 181 |
| ចំណាយលើកម្រៃជើងសា និង ប្រាក់កម្រៃ | (4,789) | (19,496) | (6,149) | (25,272) |
| ចំណាយលើកម្រៃជើងសា និង ប្រាក់កម្រៃសុទ្ធ | (4,789) | (19,496) | (6,105) | (25,091) |

## ២១. ចំណូលផ្សេងៗ

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | 19,033 | 77,483 | 14,572 | 59,891 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | 18,303 | 74,512 | 53,636 | 220,444 |
| ផ្សេងៗ | 7,535 | 30,675 | 18,668 | 76,725 |
| | 44,871 | 182,670 | 86,876 | 357,060 |

## ២២. ចំណាយលើបុគ្គលិក

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល | 671,581 | 2,734,006 | 1,230,172 | 5,056,007 |
| ចំណាយលើប្រាក់បំណាច់ អតីតភាពការងារ | 39,691 | 161,582 | 67,421 | 277,100 |
| ថ្ងៃឈប់សម្រាកប្រចាំឆ្នាំ ដែលមិនទាន់ប្រើ | 37,936 | 154,437 | 79,231 | 325,639 |
| ផ្សេងៗ | 24,780 | 100,880 | 54,374 | 223,478 |
| | 773,988 | 3,150,905 | 1,431,198 | 5,882,224 |

## ២៣. រំលស់

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| រំលស់លើទ្រព្យ និងបរិក្ខារ (កំណត់សម្គាល់ 11) | 150,638 | 613,247 | 153,554 | 631,107 |
| រំលស់លើទ្រព្យសកម្មអរូបី (កំណត់សម្គាល់ 12) | 1,122 | 4,568 | 1,118 | 4,595 |
| | 151,760 | 617,815 | 154,672 | 635,702 |

## ២៤. ចំណាយលើប្រតិបត្តិការផ្សេងៗ

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណាយលើការជួសជុល និងថែទាំ | 63,390 | 258,061 | 85,528 | 351,518 |
| ចំណាយលើការជួល | 57,776 | 235,206 | 110,884 | 455,733 |
| ចំណាយលើកម្រៃវិជ្ជាជីវៈ | 39,060 | 159,013 | 51,397 | 211,242 |
| ចំណាយលើការធ្វើដំណើរ និងដឹកជញ្ជូន | 33,072 | 134,636 | 37,733 | 155,083 |
| ចំណាយលើទំនាក់ទំនង | 31,193 | 126,987 | 40,787 | 167,635 |
| ចំណាយលើលាភការ របស់ក្រុមប្រឹក្សាភិបាល | 22,800 | 92,819 | 22,800 | 93,708 |
| ចំណាយលើទឹកភ្លើង | 21,784 | 88,683 | 26,372 | 108,389 |
| ចំណាយលើកម្រៃអាជ្ញាបណ្ណ និងប៉ាតង់ | 12,590 | 51,254 | 13,275 | 54,560 |
| ចំណាយលើសន្តិសុខ | 7,247 | 29,503 | 27,423 | 112,709 |
| ចំណាយលើសម្ភារៈការិយាល័យ | 5,508 | 22,423 | 7,720 | 31,729 |
| ចំណាយលើទីផ្សារ និងផ្សព្វផ្សាយ | 1,189 | 4,840 | 5,456 | 22,424 |
| ការចំណាយលើការលុបចោល ទ្រព្យនិងបរិក្ខារ | - | - | 30,942 | 127,171 |
| ចំណាយឱនភាពនៃតម្លៃ ទ្រព្យ និងបរិក្ខារ | - | - | 37,210 | 152,933 |
| ផ្សេងៗ | 87,148 | 354,779 | 31,660 | 130,124 |
| | 382,757 | 1,558,204 | 529,187 | 2,174,958 |

# ២៥. សម្ព័ន្ធញាតិ

## ក. អត្តសញ្ញាណរបស់សម្ព័ន្ធញាតិ

សម្ព័ន្ធញាតិ និងទំនាក់ទំនងរបស់ពួកគេជាមួយក្រុមហ៊ុនមានដូចខាងក្រោម៖

| ទំនាក់ទំនង | សម្ព័ន្ធញាតិ |
|---|---|
| ភាគទុនិក | យោងតាមកំណត់សម្គាល់ 15 |
| អ្នកគ្រប់គ្រងសំខាន់ៗ | អភិបាលរបស់ក្រុមហ៊ុនទាំងអស់ ដែលធ្វើការសម្រេចចិត្តសំខាន់ៗទាក់ទងនឹងទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងបុគ្គលិកគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងសមាជិកគ្រួសារជិតស្និទ្ធរបស់ពួកគេ)។ |

## ខ. ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

| | 2024 | | 2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ភាគទុនិក** | | | | |
| ការទូទាត់សងប្រាក់កម្ចី | - | - | (2,420,000) | (9,946,200) |
| ចំណាយការប្រាក់ | - | - | 34,012 | 139,789 |
| **សមាជិកគ្រួសារជិតស្និទ្ធរបស់ភាគទុនិក** | | | | |
| ការទូទាត់សងប្រាក់កម្ចី | - | - | (1,340,000) | (5,507,400) |
| ចំណាយការប្រាក់ | - | - | 35,193 | 144,643 |
| **អ្នកគ្រប់គ្រងសំខាន់ៗ** | | | | |
| ចំណូលការប្រាក់ពីឥណទាន | - | - | 192 | 790 |
| ប្រាក់បៀវត្សរ៍ ប្រាក់រង្វាន់ និងអត្ថប្រយោជន៍ផ្សេងៗ | 107,228 | 436,525 | 350,083 | 1,438,841 |
| ចំណាយលើលាភការរបស់ក្រុមប្រឹក្សាភិបាល | 22,800 | 92,819 | 22,800 | 93,708 |
| ចំណាយលើប្រាក់អតីតភាពការងារ | 40,632 | 165,413 | 19,795 | 81,357 |

## ២៥. សម្ព័ន្ធញាតិ (ត)

### គ. សមតុល្យជាមួយសម្ព័ន្ធញាតិ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **អ្នកគ្រប់គ្រងសំខាន់ៗ** | | | | |
| ឥណទាន | - | - | 1,121 | 4,579 |

## ២៦. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| សាច់ប្រាក់ក្នុងដៃ (កំណត់សម្គាល់ 6) | 5,889 | 23,703 | 3,618 | 14,780 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (កាលវសានដើម 3ខែ ឬតិចជាង) (កំណត់សម្គាល់ 7) | 9,785 | 39,385 | 22,431 | 91,631 |
| សមតុល្យនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា (កាលវសានដើម 3ខែ ឬតិចជាង) (កំណត់សម្គាល់ 8) | 4,622,316 | 18,604,823 | 3,514,574 | 14,357,035 |
| | 4,637,990 | 18,667,911 | 3,540,623 | 14,463,446 |

## ២៧. ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

តារាងខាងក្រោម បង្ហាញការផ្ទៀងផ្ទាត់រវាងធាតុក្នុងស្ថានភាពរបាយការណ៍ហិរញ្ញវត្ថុ និងចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ។

| | រំលស់ថ្លៃដើម | | | |
|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | 5,889 | 23,703 | 3,618 | 14,780 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 759,785 | 3,058,135 | 772,431 | 3,155,381 |
| សមតុល្យនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា | 9,955,702 | 40,071,701 | 3,514,574 | 14,357,035 |
| ឥណទានផ្ដល់ដល់អតិថិជន | 10,367,958 | 41,731,031 | 15,950,587 | 65,158,148 |
| ទ្រព្យសកម្មផ្សេងៗ | 4,900 | 19,723 | 12,807 | 52,317 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | 21,094,234 | 84,904,293 | 20,254,017 | 82,737,661 |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | - | 941 | 3,846 |
| បំណុលផ្សេងៗ | 54,612 | 219,813 | 49,991 | 204,212 |
| **បំណុលហិរញ្ញវត្ថុសរុប** | 54,612 | 219,813 | 50,932 | 208,058 |

# ២៨. កិច្ចសន្យា និងយថាភាព

## ក. ការសន្យាភតិសន្យា

ក្រុមហ៊ុន មានកិច្ចសន្យាទាក់ទិននឹងភតិសន្យាប្រតិបត្តិការលើការជួលការិយាល័យកណ្តាល និងសាខា ជាមួយចំនួនភតិសន្យាអប្បបរមានាពេលអនាគតមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| រយៈពេល 1ឆ្នាំ | 36,000 | 144,900 | 69,200 | 282,682 |
| រយៈពេល 2ឆ្នាំ ទៅ 5ឆ្នាំ | 144,000 | 579,600 | 274,200 | 1,120,107 |
| លើសពី 5ឆ្នាំ | 144,000 | 579,600 | 151,000 | 616,835 |
| | 324,000 | 1,304,100 | 494,400 | 2,019,624 |

## ខ. យថាភាពនៃពន្ធ

ក្រុមហ៊ុនវាយតម្លៃកាតព្វកិច្ចសារពើពន្ធរបស់ខ្លួន ដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធជាធរមាននានាគិតត្រឹមកាលបរិច្ឆេទរាយការណ៍។ ដោយសារតែលក្ខណៈវិវត្តន៍នៃបទប្បញ្ញត្តិសារពើពន្ធការកំណត់ពន្ធជាក់លាក់មួយចំនួន តម្រូវឲ្យប្រើប្រាស់នូវការវិនិច្ឆ័យ និងការបកស្រាយ។ អ្នកគ្រប់គ្រងបានអនុវត្តការវិនិច្ឆ័យ ក្នុងការកំណត់នូវស្ថានភាពសារពើពន្ធរបស់ក្រុមហ៊ុន និងបន្តតាមដានការវិវត្តន៍នានាលើបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ ទោះបីជាក្រុមហ៊ុនខិតខំអនុវត្តតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធនាពេលបច្ចុប្បន្នក្តី ការបកស្រាយអំពីបទប្បញ្ញត្តិសារពើពន្ធមួយចំនួនអាចមានភាពផ្សេងៗពីគ្នា។ និយ័តកម្មនានា (ប្រសិនបើមាន) ដែលជាលទ្ធផលនៃការត្រួតពិនិត្យអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិ នឹងត្រូវដាក់បញ្ចូលទៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ទៅតាមករណីជាក់ស្តែងនៅពេលដែលការត្រួតពិនិត្យត្រូវបានធ្វើឡើង និងបានបញ្ចប់សព្វគ្រប់ដោយអាជ្ញាធរពន្ធដារ។

# ២៩. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ត្រូវបានអនុវត្តដោយក្រុមហ៊ុនក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានសង្ខេបខាងក្រោមនេះ ត្រូវបានអនុវត្តដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែមានការបង្ហាញផ្សេងពីនេះ។

## ក. ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។

ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ដែលជារូបិយប័ណ្ណបរទេស ត្រូវបាន

ប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍។ ធាតុមិនមែនរូបិយវត្ថុ ដែល ត្រូវបានវាស់វែង ផ្អែកលើថ្លៃប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅ កាលបរិច្ឆេទនៃប្រតិបត្តិការ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ជាទូទៅ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

## ខ. ឧបករណ៍ហិរញ្ញវត្ថុ

ប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍។ ធាតុមិនមែនរូបិយវត្ថុ ដែល ត្រូវបានវាស់វែង ផ្អែកលើថ្លៃប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅ កាលបរិច្ឆេទនៃប្រតិបត្តិការ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ជាទូទៅ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

### (i). ការទទួលស្គាល់

ក្រុមហ៊ុនទទួលស្គាល់ជាលើកដំបូងនូវទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុន ក្លាយជាភាគីនៃកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ។
ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការ ដែលកើតមកពីការទិញ ឬបោះផ្សាយទ្រព្យសកម្ម និងបំណុលទាំងនោះ។

### (ii). ការចាត់ចំណាត់ថ្នាក់

ក្រុមហ៊ុនចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ស្របទៅតាម ផ្នែកទី11 ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន។

### (iii). ការឈប់ទទួលស្គាល់

ក្រុមហ៊ុន ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យា នៃទ្រព្យសកម្មនោះផុតកំណត់ ឬបានទូទាត់ ឬក្រុមហ៊ុន បានផ្ទេរសិទ្ធិក្នុងការទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលរាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាកម្មសិទ្ធិទាំងអស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិ ហើយក្រុមហ៊ុនមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។
ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬ លុបចោល ឬផុតអាណត្តិ។

### (iv). ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបានបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និង មាន បំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

## (v). ការវាស់វែងរំលស់ថ្លៃដើម

រំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់ប្រាក់ដើម និងបូក ឬដករំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដំបូង និងពេលដល់កាលកំណត់ ដកឱនភាពនៃតម្លៃ។

## (vi). ការវាស់វែងតាមតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែង នៅក្នុងទីផ្សារ គោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារដែលមានអត្ថប្រយោជន៍បំផុត ដែលក្រុមហ៊ុនអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យនៃការមិន អនុវត្តកាតព្វកិច្ច។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬ បំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណា ដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុង ទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើក្រុមហ៊ុនកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដោយប្រើប្រាស់តែទិន្នន័យទីផ្សារដែលអាច អង្កេតបាន ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈ ការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ នាពេលបន្តបន្ទាប់ ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើមូលដ្ឋានសមរម្យទៅតាម អាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ក្រុមហ៊ុនទទួលស្គាល់ការ ផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទរាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

## ភស្តុតាងដែលបញ្ជាក់ថាមានឱនភាពនៃតម្លៃ

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើមានភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានកត់ត្រាតាមថ្លៃដើម ឬរំលស់ថ្លៃដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលមានភស្តុតាងបញ្ជាក់ថា មានព្រឹត្តិការណ៍ខាតបង់មួយ ឬច្រើនបានកើតឡើងបន្ទាប់ពីការទទួលស្គាល់ទ្រព្យសកម្មជាលើកដំបូង ហើយដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតនៃទ្រព្យសកម្ម ដែលអាចប៉ាន់ស្មានដោយភាពជឿជាក់បាន។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការខកខានមិនបានសង ឬហួសកាលកំណត់សងរបស់អតិថិជន
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃឥណទាន ដែលក្រុមហ៊ុនមិនបានពិចារណា
- សញ្ញាណដែលបញ្ជាក់ថាអតិថិជន ឬអ្នកបោះផ្សាយ ទំនងនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រ
- ទិន្នន័យដែលអាចអង្កេត បានពាក់ព័ន្ធនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមានក្នុងស្ថានភាពនៃការ ទូទាត់របស់អតិថិជន ឬអ្នកបោះផ្សាយជាក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងការខកខានមិនបានសងជាក្រុម។

## ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម

រាល់ទ្រព្យសកម្មសារវន្ត ត្រូវបានវាយតម្លៃជាលក្ខណៈទោលសម្រាប់ឱនភាពនៃតម្លៃ។

ការវាយតម្លៃជាលក្ខណៈទោលដែលត្រូវបានរកឃើញថាមិនមានឱនភាពនៃតម្លៃជាពិសេស ត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃ ដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលស្គាល់នៅឡើយ។

សមាសធាតុទោលនៃសំវិធានធនសរុបសម្រាប់ឱនភាពនៃតម្លៃ ត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាយតម្លៃជាលក្ខណៈទោលនៃឱនភាពនៃតម្លៃ ហើយត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោល និងផ្អែកតាមការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រងលើតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ ដែលរំពឹងថានឹងទទួលបាន។ ក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃសុទ្ធដែលអាចលក់បានចំពោះទ្រព្យបញ្ចាំណាមួយ។ ទ្រព្យសកម្មដែលមាន ឱនភាពនៃតម្លៃនីមួយៗ ត្រូវបានវាយតម្លៃលើគុណសម្បត្តិរបស់វា ហើយយុទ្ធសាស្ត្រគណនា និងការ ប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលបានមកវិញ ត្រូវបានអនុម័តឯករាជ្យដោយអ្នកគ្រប់គ្រង។

សមាសធាតុជាក្រុមនៃសំវិធានធនសរុបត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមនៃឥណទានដែលមានលក្ខណៈដូចគ្នា ហើយមិនត្រូវបានចាត់ទុកថាមានលក្ខណៈទោលជាសារវន្ត និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈទោលជាសារវន្ត ប៉ុន្តែមិនត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោលនោះទេ។

សរិធានធនជាក្រុម សម្រាប់ក្រុមនៃឥណទានត្រូវទទួលមានលក្ខណៈដូចគ្នា ត្រូវបានបង្កើតឡើងដោយប្រើ វិធីសាស្រ្តស្ថិតិ ដូចជាវិធីសាស្រ្តអត្រាវិលជុំ ឬសម្រាប់ផលប័ត្រតូចៗដែលមិនមានព័ត៌មានគ្រប់គ្រាន់ វិធីសាស្រ្តផ្អែកលើបទពិសោធន៍អត្រាបាត់បង់ប្រវត្តិសាស្រ្ត។

ក្នុងការវាយតម្លៃសរិធានធនលើការខាតបង់ជាក្រុម អ្នកគ្រប់គ្រងបានពិចារណាលើកត្តាមួយចំនួនដូចជា គុណភាពឥណទាន ទំហំផលប័ត្រ ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ចជាដើម។ ដើម្បីប៉ាន់ប្រមាណនូវតម្រូវការ សរិធានធន ការសន្មតត្រូវបានធ្វើឡើងដើម្បីកំណត់ពីលក្ខណៈនៃការខាតបង់ ដែលត្រូវបានយកគំរូតាម និងការកំណត់ទិន្នន័យប៉ារ៉ាម៉ែត្រតាមតម្រូវការ ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្រ្ត និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសរិធានធនអាស្រ័យលើការសន្មតនូវគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់សរិធានធនជាក្រុម។

### ការវាស់វែង

ការខាតបង់ឱនភាពនៃតម្លៃលើទ្រព្យសកម្មដែលបានវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានគណនាដោយភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលបានប៉ាន់ស្មាននាពេលអនាគត ដែលបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដើមរបស់ទ្រព្យសកម្ម។

### ការទទួលបានមកវិញលើឱនភាពនៃតម្លៃ និងការលុបចោល

ប្រសិនបើក្នុងរយៈពេលបន្ទាប់ ចំនួននៃការខាតបង់លើឱនភាពនៃតម្លៃមានការថយចុះ ហើយការថយចុះនោះ អាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវធ្វើការកែប្រែលើការខាតបង់ឱនភាពនៃតម្លៃដែលបានទទួលស្គាល់ពីមុន ដោយផ្ទាល់ ឬដោយការធ្វើនិយ័តភាព ចំពោះគណនីសរិធានធន។

ការទទួលបានមកវិញនឹងមិនបណ្តាល ឱ្យមានចំនួនតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ក្រោយកាត់កងគណនីសរិធានធន) លើសពីចំនួនតម្លៃយោងដែលមានឱនភាពនៃតម្លៃ ដែលមិនបានទទួលស្គាល់ពីមុននោះទេ។ ក្រុមហ៊ុន ត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ដែលទទួលបានមកវិញ ក្នុងចំណេញ ឬខាតភ្លាមៗ។

ក្រុមហ៊ុន លុបចោលឥណទានផ្នែកខ្លះ ឬទាំងស្រុង និងសរិធានធនពាក់ព័ន្ធ សម្រាប់ការខាតបង់លើឱនភាពនៃតម្លៃនៅពេលដែលអ្នកគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពជាក់លាក់ក្នុងការប្រមូលបានមកវិញ។

## គ. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យនៅធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាននៅពេលតម្កល់ដំបូងមានរយៈពេល 3ខែ ឬតិចជាង ដែលអាចប្តូរជា សាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ និងត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្រ្តការប្រាក់ ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ឃ. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើប្រាស់ វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ង. ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់សំដៅលើទុនបម្រុងតាមច្បាប់ដែលត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាដោយ អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជា ភាគរយនៃដើមទុនអប្បបរមា ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់តាមច្បាប់មិនអាច ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ដូច្នេះវាមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសម្រាប់គោលបំណងនៃរបាយការណ៍លំហូរទឹកប្រាក់ឡើយ។

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ច. ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទដែលអាចទូទាត់បានតាមលក្ខណៈថេរ ឬអាច កំណត់បាន ដែលមិនមែនជាតម្លៃដកស្រង់ពីទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់នៅក្នុងពេល បច្ចុប្បន្ន ឬនៅពេលខាងមុខនោះទេ។

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែល កើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ ប្រសិទ្ធភាព។

## ឆ. ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មនានា ត្រូវបានកត់ត្រាតាមថ្លៃដើម ដកការខាតបង់នៃឱនភាពនៃតម្លៃ ប្រសិនមាន ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ជ. ទ្រព្យ និងបរិក្ខារ

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ នៅពេលដែលផ្នែកនៃទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ផ្នែកទាំងនោះ ត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ។

រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ ឬខាតលើមូលដ្ឋានរំលស់ថេរ តាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារនីមួយៗ ដូចខាងក្រោម៖

**អាយុកាលប្រើប្រាស់**

| | |
|---|---|
| ការកែលម្អទ្រព្យជួល | ទាបជាងចន្លោះ 10ឆ្នាំ ឬរយៈពេលជួល |
| យានយន្ត | 6ឆ្នាំ |
| បរិក្ខារការិយាល័យ | 4ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ | 4ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | 4ឆ្នាំ |

ទ្រព្យកំពុងបង្កើត មិនត្រូវបានរំលស់នោះទេ រហូតដល់ពេលទ្រព្យសកម្មដែលពាក់ព័ន្ធនោះត្រូវបានបញ្ចប់ និងដាក់ឱ្យប្រើប្រាស់ក្នុងប្រតិបត្តិការ។

ចំណាយបន្តបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដាដើម។ រាល់ចំណាយបន្តបន្ទាប់ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

ចំណេញ ឬខាតពីការឈប់ប្រើប្រាស់ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយ ភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ នៅក្នុងចំណេញ ឬខាត នៅពេលដែលឈប់ប្រើប្រាស់ ឬលក់ចេញ។

ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ពេល ដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបចោល។

វិធីសាស្រ្តរំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានត្រួតពិនិត្យ នាកាលបរិច្ឆេទរាយការណ៍ និងត្រូវបានកែប្រែ។

## ឈ. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានសូហ្វវែរកុំព្យូទ័រ ត្រូវបានវាស់វែងតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបី ត្រូវបានរំលស់តាមអត្រា 20% ក្នុងមួយឆ្នាំ ដោយ ប្រើប្រាស់វិធីសាស្រ្តរំលស់ថេរ។

ថ្លៃដើមដែលបានកើតឡើងក្នុងការរៀបចំផែនការ ឬវាយតម្លៃសំណើសូហ្វវែរ ឬក្នុងការថែទាំប្រព័ន្ធបន្ទាប់ពី ដាក់ឱ្យដំណើរការ មិនត្រូវបានទទួលស្គាល់ទេ។

វិធីសាស្រ្តរំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃ របាយការណ៍ និងធ្វើនិយ័តភាពប្រសិនបើសមស្រប។

### ៣. ឱនភាពនៃតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យនៃសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (ក្រៅពីពន្ធពន្យារជាទ្រព្យសកម្ម) ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារមកតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើ លំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតា បង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ជាក្នុងចំណេញ ឬខាត។

### ដ. ប្រាក់កម្ចី និងបំណុលផ្សេងៗ

ប្រាក់កម្ចី និងបំណុលផ្សេងៗ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ឋ. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើ ផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរ ទឹកប្រាក់ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

## ឌ. អត្ថប្រយោជន៍និយោជិត

### (i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានចំណាយនៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែល រំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

### (ii). ផែនការវិភាគទានដែលបានកំណត់ - មូលនិធិសោធននិវត្តន៍

កាតព្វកិច្ចសម្រាប់ការរួមចំណែក ចំពោះផែនការវិភាគទាន ដែលបានកំណត់ត្រូវបានចំណាយជាសេវាកម្ម ពាក់ព័ន្ធបានបំពេញ និងត្រូវបានទទួលស្គាល់ជាចំណាយលើបុគ្គលិក នៅក្នុងចំណេញ ឬខាត។ ការរួមចំណែកដែលបានបង់មុនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម រហូតដល់សាច់ប្រាក់ត្រូវបានបង្វិល មកវិញ ឬមានការដកចេញពីការទូទាត់នាពេលអនាគត។

### (iii). អត្ថប្រយោជន៍និយោជិតរយៈពេលវែង

កាតព្វកិច្ចរបស់ក្រុមហ៊ុនចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង គឺជាចំណាយលើអត្ថប្រយោជន៍ ដែលនិយោជិតត្រូវទទួលបាន ពីការបំពេញការងារក្នុងការិយបរិច្ឆេទកន្លងផុតទៅ និងបច្ចុប្បន្ន។ អត្ថប្រយោជន៍ និយោជិតរយៈពេលវែងត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន។ ការវាស់វែងសារជាថ្មីត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត នៅក្នុងការិយបរិច្ឆេទដែលចំណាយនេះបានកើតឡើង។

## ឍ. ដើមទុន

ថ្លៃដើមផ្ទាល់ដែលទាក់ទងនឹង ការបោះផ្សាយឧបករណ៍មូលធន ត្រូវបានទទួលស្គាល់ជាការកាត់កងចេញពីឧបករណ៍មូលធនដែលបានវាស់វែងលើកដំបូង។

## ណ. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នា រវាងឥណទានមានឱនភាពនៃតម្លៃ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងសំវិធានធនតាមបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំ លេខ ធ7-018-001 ស.រ.ច.ណ ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ នៅថ្ងៃទី5 ខែកុម្ភៈ ឆ្នាំ2025 ធនាគារជាតិនៃកម្ពុជា បានចេញលិខិតជូនដំណឹងដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ដែលតម្រូវឱ្យសំវិធានធនតាមបទប្បញ្ញត្តិ ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា គួរត្រូវគណនាដោយផ្អែកលើតម្លៃយោងដុល (រួមទាំងការប្រាក់បង្គរត្រូវទទួល) គុណនឹងអត្រាសំវិធានធននៃចំណាត់ថ្នាក់ឥណទាន នីមួយៗ ។ លក្ខខណ្ឌតម្រូវនេះ ត្រូវបានអនុវត្តចំពោះការិយបរិច្ឆេទហិរញ្ញវត្ថុដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ហើយមានសុពលភាពរហូតដល់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2025។

យោងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទានផ្តល់ដល់អតិថិជនត្រូវធ្វើ ចំណាត់ថ្នាក់តាមសមត្ថភាពសងរបស់អ្នកខ្ចី និងចំនួនថ្ងៃដែលហួសកំណត់ដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាង ឬស្មើមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា/ស្តង់ដា | <15ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | 15ថ្ងៃ ដល់ 30ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដា | 31ថ្ងៃ ដល់ 60ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | 61ថ្ងៃ ដល់ 90ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ≥ 91ថ្ងៃ | 100% |
| **ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា/ស្តង់ដា | < 30ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | ≥ 30ថ្ងៃ ដល់ 89ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដា | ≥ 90ថ្ងៃ ដល់ 179ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | ≥ 180ថ្ងៃ ដល់ 359ថ្ងៃ | 50% |
| ឥណទានបាត់បង់ | 359ថ្ងៃ ឬច្រើនជាងនេះ | 100% |

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិទាបជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនអនុលោមតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិខ្ពស់ជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដោយ អនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ខាតបង្គរទៅទុនបម្រុងតាម បទប្បញ្ញត្តិ នៅក្នុងគណនីមូលធន។

ទុនបម្រុងបទប្បញ្ញត្តិ មិនមែនជាប្រភេទដែលត្រូវបញ្ចូលក្នុងការគណនាទ្រព្យសម្បត្តិសុទ្ធរបស់ក្រុមហ៊ុននោះទេ។

## ត. ការប្រាក់

ចំណូលពីការប្រាក់ និងចំណាយលើការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព គឺជាវិធីសាស្ត្រនៃការគណនាតម្លៃរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ និងបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់ទៅតាមរយៈពេលដែលពាក់ព័ន្ធ។ “អត្រាការប្រាក់ប្រសិទ្ធភាព” គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬ រយៈពេលខ្លីជាងប្រសិនបើសមស្រប) ទៅតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុនោះ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគត ដោយពិចារណាវាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានរំពឹងទុកនាពេលអនាគតនោះទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬ បានទទួលដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែម ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

## ថ. កម្រៃ និងកម្រៃជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងការវាស់វែងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសាផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។ ប្រសិនបើ ការសន្យាផ្តល់ឥណទានមិនត្រូវបានរំពឹងថានឹងមានលទ្ធផលក្នុងការដកប្រាក់នោះ កម្រៃពីការសន្យាផ្តល់ ឥណទានពាក់ព័ន្ធ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមថិរវេលានៃកិច្ចសន្យា។
ចំណាយកម្រៃ និងជើងសាផ្សេងៗ ពាក់ព័ន្ធជាចម្បងលើកម្រៃប្រតិបត្តិការ និងសេវាកម្ម ត្រូវបានចំណាយ នៅពេលសេវាកម្មត្រូវបានទទួល។

## ទ. ភតិសន្យា

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌនៃភតិសន្យា ផ្ទេររាល់ហានិភ័យ និងអត្ថប្រយោជន៍នៃកម្មសិទ្ធិនៃទ្រព្យទាំងអស់ឱ្យស្ថិតនៅក្រោមក្រុមហ៊ុន។ ភតិសន្យាផ្សេងៗទៀត គឺត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។

ការទូទាត់ភតិសន្យាដែលធ្វើឡើងក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតតាមមូលដ្ឋានថេរទៅតាមរយៈពេលនៃការជួល។ ប្រាក់លើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃចំណាយភតិសន្យាសរុបក្នុងរយៈពេលនៃការជួល។

## ធ. ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ វាត្រូវបានទទួលស្គាល់នៅក្នុង ចំណេញ ឬខាត លើកលែងតែធាតុណាបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬនៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

### (i). ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ ឬត្រូវទទួលលើប្រាក់ចំណេញ ឬខាតជាប់ពន្ធ ប្រចាំឆ្នាំ និងនិយ័តភាពលើពន្ធដែលត្រូវបង់ ឬត្រូវទទួលដែលទាក់ទងទៅនឹងការិយបរិច្ឆេទមុនៗ។ ចំនួននៃពន្ធដែលត្រូវបង់ ឬត្រូវទទួលប្រចាំឆ្នាំ គឺជាការប៉ាន់ស្មានដ៏ល្អបំផុតនៃចំនួនពន្ធដែលរំពឹងថានឹងត្រូវបង់ ឬ ត្រូវទទួល ដែលឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់ទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ប្រសិនបើមាន។ វាត្រូវបានវាស់វែងដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

(ii). ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់លើភាពលម្អៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ការខាតពន្ធមិនបានប្រើប្រាស់ ឥណទានពន្ធមិនបានប្រើប្រាស់ និងភាពលម្អៀងជាបណ្តោះអាសន្នដែលអាចកាត់កងបាន តែក្នុងករណីអាចនឹងកើតមានឡើងលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអាចប្រើប្រាស់បាន។ ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ត្រូវបានកំណត់ដោយផ្អែកលើផែនការអាជីវកម្មរបស់ក្រុមហ៊ុន និងភាពខុសគ្នាបណ្តោះអាសន្នពីចំនួនដែលទទួលបានមកវិញ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវបានកាត់បន្ថយក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធ ដែលអាចនឹងប្រើប្រាស់បាន។

ពន្ធពន្យារជាទ្រព្យសកម្មដែលមិនបានទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់តែក្នុងករណីដែលអាចនឹងកើតមានឡើងនូវអត្ថប្រយោជន៍ជាប់ពន្ធនាពេល អនាគតដែលអាចប្រើប្រាស់បាន។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានកំណត់ដោយប្រើអត្រាពន្ធ ដែលរំពឹងថានឹងប្រើលើភាពលម្អៀងជា បណ្តោះអាសន្នដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារឆ្លុះបញ្ចាំងពីលទ្ធផល ដែលក្រុមហ៊ុនរំពឹងថា (នៅកាលបរិច្ឆេទរាយការណ៍) នឹងទទួលបានមកវិញ ឬការកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលពន្ធពន្យារ អាចកាត់កងគ្នាបាន ក្នុងករណីច្បាប់បានអនុញ្ញាត ហើយមានការទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលបានកំណត់ ដោយអាជ្ញាធរពន្ធលើស្ថាប័នតែមួយ ឬលើអង្គភាព ពន្ធតែមួយដើម្បីទូទាត់បំណុលពន្ធប្រចាំឆ្នាំ និងទ្រព្យសកម្ម ឬពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលពន្ធពន្យារនឹងត្រូវបានទទួលស្គាល់ក្នុងពេលដំណាលគ្នា។

## ឧ. ស្តង់ដាគណនេយ្យដែលបានចេញផ្សាយ ប៉ុន្តែពុំទាន់ចូលជាធរមាន

នៅខែកុម្ភៈ ឆ្នាំ2025 ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (IASB) បានបោះផ្សាយនូវស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ សម្រាប់ ស.ត.ម") ជំនាន់ទីបី ដែលនឹងត្រូវយកមកអនុវត្តដំណាលគ្នានឹងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម")។ ស្តង់ដានេះចូលជាធរមាន សម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំ ដែលចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2027។ ទោះបីជាការអនុវត្តជាមុនត្រូវបានអនុញ្ញាត ក្រុមហ៊ុនអាចជ្រើសរើសការអនុវត្តស្តង់ដាថ្មីនេះចាប់ពីកាលបរិច្ឆេទចូលជាធរមាន។ វិសោធនកម្មនេះបាននាំមកនូវការកែប្រែជាសារវន្តនានាទៅលើផ្នែកគណនេយ្យផ្សេងៗជាច្រើន ដើម្បីធ្វើឱ្យ ស.រ.ទ.ហ.អ សម្រាប់ ស.ត.ម កាន់តែស្របគ្នាជាងមុនទៅនឹងបច្ចុប្បន្នភាពនៃស្តង់ដាគណនេយ្យស.រ.ទ.ហ.អ។ វិសោធនកម្មសំខាន់ៗរួមមានការកែប្រែការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ ការទទួលស្គាល់ប្រាក់ចំណូល ឧបករណ៍ហិរញ្ញវត្ថុ ការរួមបញ្ចូលគ្នា ភតិសន្យា និងការរាយការណ៍ផ្សេងៗទៀត។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងកំពុងធ្វើការវាយតម្លៃពីសក្តានុពលនៃផលប៉ះពាល់ពីវិសោធនកម្មទាំងនេះមកលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមទាំងនិយ័តភាពចាំបាច់នានា លើគោលនយោបាយគណនេយ្យ ការលាតត្រដាងព័ត៌មាន និងដំណើរការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ។


ផ្ដល់កម្ចីរហូតដល់
$50,000
ឥណទាន
ប្រើប្រាស់ផ្ទាល់ខ្លួន
ការសងត្រឡប់មានភាពបត់បែន
អត្រាការប្រាក់សមរម្យ
ងាយស្រួល និងឆាប់រហ័ស

# អាសយដ្ឋានការិយាល័យកណ្ដាល និង សាខា

## ការិយាល័យកណ្ដាល

អគារលេខ ៥០២ហេ្យ-៥០២ហាស មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (ទល់មុខវ៉ាដាតេជោសែន)
ទូរស័ព្ទ : (៨៥៥) ២៣ ៩៩ ៣៣ ៣៣ / ០៩៣ ៩៩ ៦៦៦៦
អ៊ីម៉ែល : info@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## សាខា ចំការមន

អគារលេខ ៥០២ហេ្យ-៥០២ហាស មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ៩៣ ២២២ ៧៩៩
អ៊ីម៉ែល : bm_ckm@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## សាខា ក្រុងតាខ្មៅ

ភូមិព្រែកខ្សេវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរស័ព្ទ : (៨៥៥) ៩៣ ២២២ ៨៧១
អ៊ីម៉ែល : bm_sng@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

# ការិយាល័យកណ្តាល

អគារលេខ ៥០២G, ៥០២H មហាវិថីព្រះមុនីវង្ស
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

(៨៥៥) ២៣ ៩៩ ៣៣៣៣
(៨៥៥) ៩៧ ៧៦១ ៣៣៣៣

hr@samrithisak.com

facebook.com/samrithisakmfi